# ទំនៀមទម្លាប់ប្រពៃណីខ្លះប្រារព្ធនៅចុងរដូវវស្សា (ភាគ១)

ចុងរដូវវស្សា គឺជាពេលវេលាមួយរយៈខ្លី ដែលគេសង្កេតឃើញអ្នកស្រែភាគច្រើនទំនេរដៃ ផ្អាកពីការងារដកស្ទូងស្រូវស្រែ។ ចំពោះអ្នកស្រុករស់នៅតាមដងទន្លេ ក្នុងវេលាចុងរដូវវស្សា ឬគេតែងហៅថារដូវទឹកស្រក គឺជាពេលដែលគេរង់ចាំទឹកស្រកដកថយលេចបានផ្ទៃដីធំទូលាយសម្រាប់ដាំដុះបង្កើនបង្កើនផលដំណាំផ្សេងៗ។ ក្នុងអំឡុងពេលខ្លីនេះគេក៏អាចហៅជារួមបានថា "ចុងឆ្នាំ" ពោលគឺឆ្នាំនៃវដ្តស្រូវ[1] មុននឹងចូលឆ្នាំថ្មីក្នុងខែចេត្រ (ឆ្នាំចន្ទគតិ)។[2] ក្នុងពេលនេះជាទូទៅគេសង្កេតឃើញអ្នកស្រុកតាមតំបន់នានា តែងប្រារព្ធពិធីផ្សេងៗតាមទំនៀម និងទម្លាប់ស្រុកភូមិរៀងៗខ្លួន ដោយពិធីខ្លះបានផ្សារភ្ជាប់នឹងព្រះពុទ្ធសាសនាផង ហើយពិធីខ្លះទៀតមានរៀបចំល្បែងលេងប្រឡងប្រណាំងកម្សាន្តសប្បាយតាមចំណាំផង។

ជាការពិតក្នុងវស្សារយៈពេលបីខែ (១រោច ខែអាសាឍ ដល់ ១៥កើត ខែអស្សុជ) ខ្មែរពុំដែលរៀបចំកិច្ចពិធីអ្វីធំដុំទេ ពិសេសពិធីមង្គលការកូនចៅ សង់ផ្ទះថ្មី ឬឡើងផ្ទះថ្មីឡើយ ដ្បិតខ្មែរកាន់តំណមតឹងរ៉ឹងខ្លះយល់ថានៅក្នុងវស្សា គឺជាពេលឥតមានឫក្សល្អ ឥតមានជោគជ័យ និងឥតមានស្រីសួស្តី វៀរលែងតែបុណ្យខ្មោចដែលចៀសខានមិនប្រារព្ធមិនបាន។[3] ប៉ុន្តែលុះចាប់ពីត្រឹមរវាងមុននិងក្រោយចេញវស្សាបន្តិច គេសង្កេតឃើញកិច្ចពិធីជាទំនៀមនិងទម្លាប់ខ្លះ ចាប់ផ្តើមប្រារព្ធជាហូរហែទៅតាមទំនៀមនិងទម្លាប់ស្រុកភូមិនីមួយៗ។ បើរៀបរាប់ដោយសង្ខេប កិច្ចពិធីតូចធំទាំងនោះមានដូចជា បុណ្យបវរណាចេញវស្សា (ចេញព្រះវស្សា) ការលេងប្រណាំងទូកតាមទម្លាប់អ្នកស្រុក ដង្ហែអង្គកឋិនតាមវត្តនីមួយៗ ពិធីបណ្តែតប្រទីប សំពះព្រះខែ អកអំបុក បុណ្យដារលាន បុណ្យទេសន៍មហាជាតក៍ ការលេងបង្ហើរខ្លែង និងពិធីឡើងមាយ ឬឡើងអ្នកតាជាដើម។ ខាងក្រោមនេះ គឺជាសេចក្តីសង្ខេបនៃទំនៀមនីមួយៗប្រារព្ធនាចុងរដូវវស្សា។

---

[1] សូមអានបន្ថែម៖ ភិន សំណាង ២០១១

[2] ឆាន់ សុភីនី, សោ ចន្ទា, តូច សុក:, ជា សំបូរ, អាន សីមា, និង អ៊ូ គង្គា ២០២១: ១៨៣

[3] ធឹង ផាន់សុផុន ២០០០: ៣៤២

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

## ក.ចេញព្រះវស្សា

ពិធីចេញព្រះវស្សា ឬបុណ្យបវរណាចេញព្រះវស្សា គឺជាទំនៀមក្នុងពុទ្ធសាសនាប្រារព្ធក្នុងថ្ងៃ១៥កើត ពេញបូណ៌មី ខែអស្សុជ។ វេលានេះ បើមើលទំនៀមក្នុងព្រះបរមរាជវាំង គេឃើញក្រុមបារគូតែងធ្វើពិធីយាងទេវរូបចេញព្រះវស្សាប្រារព្ធនៅក្នុងព្រះទីនាំងទេវាវិនិច្ឆ័យ ដោយមានប្រារព្ធទេសនាគាថាពាន់ផង (រូបលេខ១)។ ក្នុងថ្ងៃជាមួយគ្នានេះដែរ នៅគ្រប់វត្តអារាមនានា ព្រះសង្ឃក៏ប្រជុំគ្នាធ្វើកិច្ចបវរណាចេញព្រះវស្សា សុំខមាទោសកំហុសរបស់ខ្លួនគ្រប់ព្រះអង្គ (រូបលេខ២)។ ចំណែកឯពុទ្ធបរិស័ទក៏ជ្រះថ្លាធ្វើទានប្រគេនព្រះសង្ឃទៅតាមទំនៀម ហើយនៅតាមវត្តខ្លះក៏មាននិមន្តព្រះសង្ឃទេសន៍មហាជាតក៏ក្នុងពេលនេះដែរ (រូបលេខ៣)។



រូបលេខ១ ព្រះរាជពិធីចេញព្រះវស្សាក្នុងព្រះបរមរាជវាំង (ឆ្នាំ២០១៩) (រូបថត៖ norodomsihamoni.org)





រូបលេខ២-៣ ព្រះសង្ឃបវរណាចេញព្រះវស្សា ទេសនាមហាជាតក៏នៅតាមវត្ត (រូបថត៖ មាស សុភាព)

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

## ២.ប្រណាំងទូក

ដោយឡែកក្នុងរវាងចេញព្រះវស្សានេះដែរ ចំពោះអ្នកស្រុករស់នៅតាមដងទន្លេ ឬរស់នៅតាមតំបន់ផ្លូវទឹកធំៗ តែងស្រុះស្រួលគ្នារៀបចំលេងប្រណាំងទូកទៅតាមរបៀប និងទម្លាប់អ្នកស្រុក។ ទូកនីមួយៗច្រើនតែជាប្រភេទទូក-ង ដឹកនាំកសាងដោយព្រះចៅអធិការវត្ត ហើយរក្សាទុកជាសម្បត្តិរួមរបស់អ្នកស្រុកនៅក្នុងវត្តតែម្តង។ នៅតាមវត្តខ្លះ ចាប់ពីថ្ងៃភ្ជុំមកគេឃើញចាប់ផ្តើមរៀបចំសម្អាត ជួសជុលទូក និងធ្វើកិច្ចប្រុងពាលីដាក់ទូកពីបង្គង ចុះទឹកហាត់អុំសម្រាប់ត្រៀមប្រណាំងជាមួយទូកវត្តផ្សេងៗនៅក្នុងថ្ងៃភ្ជុំធំ ឬក្នុងថ្ងៃចេញព្រះវស្សា (រូបលេខ៤)។ តាមសង្កេត ការប្រណាំងទូកតាមស្រុកភូមិនីមួយៗតែងតែធ្វើមុនព្រះរាជពិធីអុំទូកថ្នាក់ជាតិ ដ្បិតជាទូទៅគេច្រើនរើសយកទូកល្អៗពីភូមិស្រុកនានាមកចូលរួមប្រណាំងនៅមុខព្រះរាជដំណាក់ផែនៃទន្លេចតុមុខ មុខព្រះបរមរាជវាំង។[4] សព្វថ្ងៃគេសម្គាល់ឃើញអ្នកស្រុកជលគិរី (ខេត្តកំពង់ឆ្នាំង) តែងរៀបចំប្រណាំងទូកនៅដងទន្លេសាប ក្រោយវត្តកោះថ្កូវ នៅក្នុងថ្ងៃភ្ជុំធំ។ ចំណែកឯនៅកោះដាច់ (ខណ្ឌជ្រោយចង្វារ) នៅល្វាឯម និងនៅវត្តជ្រោយអំពិល អ្នកស្រុកច្រើនរៀបចំប្រណាំងក្នុងថ្ងៃចេញព្រះវស្សា (រូបលេខ៥-៦)។[5] សូមបញ្ជាក់ថា ការប្រណាំងទូកតាមទម្លាប់អ្នកស្រុកឃើញមានចាប់តាំងពីភ្ជុំរហូតដល់កឋិនក៏មានដែរ។



រូបលេខ៤ រៀបចំជួសជុលទូកត្រៀមអុំក្នុងថ្ងៃចេញវស្សា



រូបលេខ៥ ប្រណាំងទូកនៅវត្តកោះថ្កូវ (រូប៖ ស៊ុំ កុសល)



រូបលេខ៦ ប្រណាំងទូកនៅវត្តក្បាលកោះ (កោះដាច់)

---

[4] សូមអាន៖ "ទូកប្រណាំងនិងទំនៀមអ្នកស្រុក (ភាគ១) ដោយ ហៀន សុវណ្ណមរកត ផ្សាយលើតំណ https://ams.com.kh/khmercivilization/detail/24926

[5] គេសង្កេតឃើញថា ការប្រណាំងទូកនៅតាមស្រុកនានាក្នុងពេលសព្វថ្ងៃ បានយកលំនាំច្រើនតាមរបៀបរៀបចំនៅមុខព្រះបរមរាជវាំង។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

**គ.កឋិនទាន**

តាមទំនៀមព្រះពុទ្ធសាសនាក្នុងសង្គមខ្មែរ ក្នុងរយៈពេល២៩ថ្ងៃដែលរាប់ជាកឋិនកាល (១រោច ខែអស្សុជ ដល់ ១៥កើត ខែកត្តិក) ពុទ្ធបរិស័ទតែងមូលមតិគ្នាផ្តួចផ្តើមរៀបចំអង្គកឋិន ដើម្បីដង្ហែទៅវេរប្រគេនដល់ព្រះសង្ឃគង់ចាំព្រះវស្សាអស់ត្រីមាសរយៈពេល៣ខែ។ ក្នុងរយៈពេលនេះ ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់តែងចេញថតព្រះកឋិនវេរប្រគេនព្រះសង្ឃតាមវត្តនានាក្នុងទីក្រុងនិងខេត្តក្រៅខ្លះ តាមដែលទ្រង់សព្វព្រះរាជហឫទ័យហៅថា "អង្គព្រះកឋិនទានព្រះរាជទ្រព្យ"[6] ព្រះមហាក្សត្រអាចយាងផ្ទាល់ព្រះអង្គ ឬចាត់ព្រះរាជតំណាងចូលដង្ហែអង្គព្រះកឋិននោះក៏បាន។

ដោយឡែកនៅក្នុងរយៈពេលនៃកឋិនកាលនេះ បើវត្តណាពុំមានអង្គកឋិនដង្ហែចូលទៅ នោះពុទ្ធបរិស័ទចំណុះជើងវត្តតែងតែមូលមតិរៃអង្គាសប្រាក់តាមភូមិ រៀបចំឱ្យកើតជាកឋិនឡើងមិនដែលខាន (រូបលេខ៧-៨)។ ទិដ្ឋភាពនេះហាក់ស្តែងឱ្យឃើញថាកឋិនជាបុណ្យក្នុងព្រះពុទ្ធសាសនាដ៏សំខាន់ ប្រកបដោយភាពឱឡារិក សប្បាយរីករាយសាមគ្គី និងបានផ្សារភ្ជាប់យ៉ាងស្អិតរមួតនឹងសង្គមខ្មែរ រហូតក្លាយជាទំនៀមបុណ្យយ៉ាងឱឡារិកក្រៃលែងបំផុតនាចុងរដូវភ្លៀង។




**រូបលេខ៧-៨ ទិដ្ឋភាពដង្ហែ និងវេរអង្គកឋិនទានប្រគេនព្រះសង្ឃតាមទំនៀម**

[6] ចាប ពិន ១៩៦០: ៩៩-១១៨

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

### ឃ.បណ្ដែតប្រទីប សំពះព្រះខែ អកអំបុក

បើយកតាមប្រតិទិនចន្ទគតិ ពីថ្ងៃ១៤-១៥កើត ដល់ថ្ងៃ១រោច ខែកត្តិក កំណត់ជា "ព្រះរាជពិធីបុណ្យអុំទូក បណ្ដែតប្រទីប និងសំពះព្រះខែ អកអំបុក" ប្រារព្ធយ៉ាងឱឡារិកក្នុងព្រះបរមរាជវាំង និងនៅមុខព្រះរាជដំណាក់ផែទន្លេចតុមុខ។ ពិធីបណ្ដែតប្រទីប សំពះព្រះខែ និងអកអំបុកដែលនិយាយមកខាងដើម ក៏តែងសង្កេតឃើញអ្នកស្រុកប្រារព្ធជាប្រក្រតីតាមទំនៀម តែពុំសូវធ្វើពិធីរួមទាំងអស់ក្នុងពេលតែមួយឡើយ។ ដូចបានរៀបរាប់ក្នុងចំណុចខាងលើ អ្នកស្រុកតែងប្រណាំងទូកចាប់ពីថ្ងៃភ្ជុំបិណ្ឌដល់ចេញព្រះវស្សា។ ក្នុងយប់ចេញព្រះវស្សានោះសោត ទើបគេធ្វើកិច្ចបណ្ដែតប្រទីប (និងកន្ទោងផង) (រូបលេខ៩)។ ប៉ុន្តែពិធីសំពះព្រះខែ និងអកអំបុកគេប្រារព្ធក្នុងថ្ងៃ១៥កើត ខែកត្តិក។

ចំពោះពិធីសំពះព្រះខែ អកអំបុក អ្នកស្រុកខ្លះហៅដោយខ្លីក្នុងន័យរួមថា "បុណ្យអកអំបុក" ឬ "បុណ្យមហាអំបុក"[7] (រូបលេខ១០) ឬអ្នកស្រុកភាគខាងជើងហៅថា "អកព្រះខែ" ឬ "បង្អកព្រះខែ"។[8] តាមសង្កេតគេច្រើនឃើញយុវជនជំទង់ៗចូលរួម ហើយតែងប្រារព្ធធ្វើនៅក្នុងវត្ត ដោយការចាប់ផ្ដើមបុកអំបុកនោះតាំងពីព្រលប់ រហូតដល់ពាក់កណ្ដាលអាធ្រាត្រ ពេលដែលព្រះចន្ទរំកិលត្រង់ចំលើក្បាលទើបគេធ្វើកិច្ចសំពះព្រះខែ និងអកអំបុក (រូបលេខ១១)។ ក្នុងវេលាពាក់កណ្ដាលអាធ្រាត្រនៃថ្ងៃពេញបូណ៌មីនោះ នៅតាមវត្តខ្លះថែមទាំងរៀបចំកិច្ចសម្រក់ទៀនផ្សងទឹកភ្លៀងឆ្នាំថ្មីដែរ។



រូបលេខ៩ អ្នកស្រុកបណ្ដែតប្រទីបក្នុងទន្លេមេគង្គ (មុខវត្តរកាអារ)



រូបលេខ១០ ការរៀបចំប្រារព្ធពិធីសំពះព្រះខែ និងអកអំបុកនៅតាមវត្ត



រូបលេខ១១ បង្អកព្រះខែនៅវត្តត្រាច ខេត្តសៀមរាប (រូបថត៖ អាំង ជូលាន, យសោធរ)

---

[7] មៀច ប៉ុណ្ណ ១៩៩៤: ៦៩-៧៦

[8] ភិន សំណាង ២០១១: ៥៩ និង អាំង ជូលាន ២០១៦: ១០៤-១០៦

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

សង្ខេបសេចក្ដីមក ពិធីជាទំនៀម និងល្បែងប្រពៃណីដែលអ្នកស្រុកតែងប្រារព្ធនិងលេងនៅក្នុងវេលាខ្លីនៃចុងរដូវវស្សា មានច្រើនប្រការណាស់ ហើយមានន័យនិងខ្លឹមសារជាប់នឹងផ្នត់គំនិតអ្នកស្រុកជាដរាប។ ដូច្នេះនៅក្នុងអត្ថបទភាគ២ ខ្ញុំនឹងរៀបរាប់បញ្ចប់នូវពិធី ឬកិច្ចជាទំនៀម និងល្បែងប្រពៃណីដែលលេងជាទម្លាប់របស់អ្នកស្រុកក្នុងវេលាចុងឆ្នាំជាសេចក្ដីបញ្ចប់៕

## ឯកសារយោង


ចាប ពិន

១៩៦០, *ព្រះរាជពិធីទ្វាទសមាស*, ភាគ៣, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ

ផាន់ សុភីនី, សោ ចន្ទា, តូច សុគៈ, ជា សំបូរ, អាន សីមា, និង អ៊ូ គន្ធា

២០២១, "កិច្ចពិធីនៅចុងរដូវស្រូវ៖ ករណីឡើងមាឃនៅភូមិបង្កោង", *ព្រះនគរ*, លេខ២៣, ទំ.១៨៣-១៩៦, អាជ្ញាធរជាតិអប្សរា, សៀមរាប

ធឹង ផាន់សុផុន

២០០០, *បុណ្យទំនៀមខ្មែរ៖ ក្រាំងបុណ្យទាំង១២ខែ*, ភាគ២, សាកលវិទ្យាល័យបញ្ញាសាស្ត្រ, ភ្នំពេញ

ភិន សំណាង

២០១១, *ស្រូវក្នុងប្រពៃណីខ្មែរ*, នគរវត្ត, ភ្នំពេញ

មៀច ប៉ុណ្ណ

១៩៩៦, "បុណ្យមហាអំបុក (តាមទំនៀមរបស់ប្រជាជននៅខេត្តតាកែវ)", *កម្ពុជសុរិយា*, ឆ្នាំទី៤៩ លេខ២, ទំ.៦៩-៧៦, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ

ហៀន សុវណ្ណមរកត

២០២២, "ទូកប្រណាំងនិងទំនៀមអ្នកស្រុក (ភាគ១) ផ្សាយលើគេហទំព័រ https://ams.com.kh/khmercivilization/detail/24926


អត្ថបទដោយ៖ ហៀន សុវណ្ណមរកត